# ព្រះរាជក្រឹត្យ

នស/រកត/០៧០០/១២៥

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល

## ក្រសួងមហាផ្ទៃ

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៣ខែ មិថុនា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **ឃ** ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា ២.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ។

**មាត្រា ៣.-**

មន្ត្រីរាជការ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិមុខងារសាមញ្ញ នៅក្នុងអង្គភាពរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង។

## ជំពូកទី ២

## ឋានន្តរស័ក្តិ នៃក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលមាន ៣ ឋានន្តរសក្តិ ៖

- នាយភ្នាក់ងាររដ្ឋបាល : មាន ០៦ ថ្នាក់
- ភ្នាក់ងាររដ្ឋបាលដើមខ្សែ : មាន ១០ ថ្នាក់
- ភ្នាក់ងាររដ្ឋបាល : មាន ១៤ ថ្នាក់។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវធ្វើតាមរយៈការប្រឡងប្រជែងដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ។ ចំនួននៃតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៦.-**

ការប្រឡងប្រជែងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង។ អាយុនេះអាចរំកិលពី២៥ឆ្នាំឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

## ជំពូកទី ៤

## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជនដែលត្រូវបានជ្រើសរើស ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមមាត្រា១៦ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីទាំងនេះត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិភ្នាក់ងាររដ្ឋបាល ឬក្នុងករណីចាំបាច់ អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែមដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ

ត្រូវបានលុបឈ្មោះចោល។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ០៣ខែ ក្រោយការបញ្ចប់កម្មសិក្សា។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ៨.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិមួយរួចហើយ មន្ត្រីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃទាំងនេះ ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលស្របជាមួយឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុង ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ៩.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម៖

- គោរពវិន័យការងារបានត្រឹមត្រូវ
- សំរេចបានល្អនូវភារកិច្ចដែលប្រគល់អោយ
- មានសីលធម៌ល្អ ។

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព។

**មាត្រា ១០.-**

គោលការណ៍នៃការតម្លើងឋានន្តរសក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរសក្តិ ត្រូវអនុវត្តឱ្យបានស្របជាមួយចំនួនតំណែងដែលទំនេរ នៅក្នុងឋានន្តរសក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរសក្តិ ឬតាមរយៈការប្រឡងប្រជែង ដោយរក្សាគោលការណ៍គិតជាភាគរយ ៖

- ឋានន្តរសក្តិនាយភ្នាក់ងាររដ្ឋបាល = ៥ ភាគរយ
- ឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ ភាគរយ
- ឋានន្តរសក្តិភ្នាក់ងាររដ្ឋបាល = ៧០ ភាគរយ

ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរសក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ១១.-**

អាចតម្លើងទៅក្នុងឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយណា ដែលបានឡើងដល់ថ្នាក់

លេខ ១១ នៃឋានន្តរសក្តិភ្នាក់ងាររដ្ឋបាល។

អាចតម្លើងទៅក្នុងឋានន្តរសក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយណា ដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ។

**មាត្រា ១២.-**

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរសក្តិនីមួយៗ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតម្លៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗ ទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៣.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវដាក់អោយចូលនិវត្តន៍នៅពេលដល់អាយុ៥៥ ឆ្នាំ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវកសាងចេញពីសមាហរណកម្ម នៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដ របស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និងតាមខេត្ត ក្រុង។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១៦.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ១៧.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខៈ ១៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ណាឌី តាន់**